THE SCHOOL DISTRICT OF PHILADELPHIA

**OFFICE OF THE SUPERINTENDENT**
440 North Broad Street
Philadelphia, PA 19130

**Dr. Tony B. Watlington, Ed.D.**
Superintendent

ថ្ងៃទី ៦ ខែ កក្កដា ឆ្នាំ ២០២៣




ជូនចំពោះ ក្រុមគ្រួសាររបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា៖

ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ាមានសេចក្តីសោមនស្សរីករាយក្នុងការប្រកាសអំពី ***ការប្រារព្ធពិធីត្រឡប់មករៀនវិញ និងរថយន្តសាលាដែលធ្វើដំណើរឆ្លងកាត់តំបន់របស់លោកអ្នកប្រចាំខួបលើកទី ៣ (3rd Annual Back-to-School Celebration & Bus Tour)***! យើងមានសេចក្តីរំភើបចិត្តក្នុងការធ្វើដំណើរឆ្លងកាត់ទីក្រុងហ្វីឡាដែលហ្វ្យ៉ាដោយរថយន្តសាលា ដើម្បីជួយក្រុមគ្រួសារឱ្យត្រៀមខ្លួនសម្រាប់ថ្ងៃចូលរៀនដំបូងក្នុងឆ្នាំសិក្សា ២០២៣-២០២៤ – គឺនៅថ្ងៃ អង្គារ ទី ៥ ខែ កញ្ញា។

ដូចឆ្នាំមុនៗ ការធ្វើដំណើរឆ្លងកាត់តំបន់លោកអ្នកដោយរថយន្តសាលាត្រូវបានផ្តល់ប្រាក់ឱ្យដោយជំនួយដ៏សប្បុរសពី Independence Blue Cross Foundation និងផ្តល់ព័ត៌មានសំខាន់ៗអំពីការត្រឡប់មករៀនវិញ និងសេវាកម្មផ្សេងៗក្នុងតំបន់របស់លោកអ្នក។ ពីថ្ងៃទី ៣១ ខែ កក្កដា ដល់ ថ្ងៃទី ១៨ ខែ សីហា រថយន្តសាលានឹងធ្វើដំណើរឆ្លងកាត់ទីក្រុងហ្វីឡា ដែលមានព្រឹត្តិការណ៍ចំនួនដប់មួយ រួមទាំងព្រឹត្តិការណ៍ធំៗដ៏គួរឱ្យរំភើបចំនួន ៥ ដែលរួមការឧបត្ថម្ភដោយដៃគូផ្សេងៗ រួមមាន Radio One, Office Depot និង Roosevelt Mall ។ នៅក្នុងព្រឹត្តិការណ៍ទាំងនេះ លោកអ្នកអាច៖

- រីករាយជាមួយអាហារសម្រន់ និងអាហារត្រជាក់ៗ
- ចូលរួមក្នុងសកម្មភាពអប់រំជាអន្តរកម្មជាមួយកូនរបស់លោកអ្នក
- ជជែកជាមួយ អ្នកតំណាងនៃក្រុមតាមផ្លូវ (Street Team Ambassadors) របស់យើង ដើម្បីទទួលព័ត៌មានអំពីការត្រឡប់មករៀនវិញដែលលោកអ្នកត្រូវការ
- ចុះឈ្មោះកូនរបស់លោកអ្នកសម្រាប់ថ្នាក់មុនមត្តេយ្យ ដល់ថ្នាក់ទី ១២
- ចុះឈ្មោះសម្រាប់គណនី គេហទំព័រសម្រាប់មាតាបិតា (Parent Portal)
- ទទួលសំពៀតដាក់សៀវភៅ និងសម្ភារៈសិក្សា *ដោយឥតគិតថ្លៃ*
- នៅព្រឹត្តិការណ៍ធំៗមួយចំនួន សូមឱ្យកូនរបស់លោកអ្នកទទួលការចាក់ថ្នាំបង្ការរោគ និងការពិនិត្យរាងកាយដែលត្រូវការដើម្បីចូលរៀន ***ដោយឥតគិតថ្លៃ*** និងអ្វីៗជាច្រើនទៀត។

**ស្វែងរកកាលវិភាគសម្រាប់ការធ្វើដំណើរដោយរថយន្តសាលាដែលឆ្លងកាត់តំបន់របស់លោកអ្នក ព័ត៌មានថ្មីៗអំពីការត្រឡប់មករៀនវិញ និងព័ត៌មានអំពីការចាក់ថ្នាំបង្ការរោគ នៅក្នុងគេហទំព័រ** [philasd.org/ringthebell](philasd.org/ringthebell) ឬដោយហៅទូរសព្ទទៅលេខ **215-400-4000**។ ខ្ញុំសង្ឃឹមថានឹងឃើញលោកអ្នកនៅចំណតរថយន្តសាលាមួយ ក្នុងចំណោមចំណតជាច្រើន នៅរដូវក្ដៅនេះ ហើយទន្ទឹងរង់ចាំការវាយកណ្ដឹងនៅឆ្នាំសិក្សាថ្មី ក្នុងរដូវស្លឹកឈើជ្រុះនេះ។

ក្នុងភាពជាដៃគូ

*Tony*

Tony B. Watlington Sr., Ed.D.
អគ្គនាយកក្រសួងអប់រំ
ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា